# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 09-Jun-2020, 14:21
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# ការឆ្លើយតបចំពោះ ខៀវ សំផន ទាក់ទងការមិនអនុវត្តតាមមាត្រា ៦ នៃសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារ

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខតំណាង ដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Megan HIRST

**សហមេធាវីតំណាង ដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី

**ដាក់ជូន៖**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល**

ចៅក្រម គង់ ស្រីម ប្រធាន

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវុឌ្ឍ

ចៅក្រម Florence Ndepele MWACHANDE-MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ហុង គីមសួន

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ិន

សំ សុគង់

វ៉េន ពៅ

ទី ស្រីនណា

Olivier BAHOUGNE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Nushin SARKARATI
Mahesh RAI

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា**

ជា លាង

Brenda J. HOLLIS

**សហមេធាវីការពារក្តី**

គង់ សំអុន

Anta GUISSÉ

## I. សេចក្តីផ្តើម

1. ការឆ្លើយតបនេះត្រូវបានដាក់ដោយ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមមាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ដើម្បីឆ្លើយតបចំពោះបញ្ហាថ្មី ដែលបានលើកឡើងនៅក្នុង*ចម្លើយតបរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់* (“ចម្លើយតបរបស់មេធាវីការពារក្តី”)[1]។

## II. ការដាក់ឯកសារដែលត្រឹមត្រូវ

2. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កោតសរសើរចំពោះការទទួលស្គាល់ របស់មេធាវីការពារក្តី ដែលថាមានតម្រូវការក្នុងការកែតម្រូវបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់របស់ខ្លួន ហើយនិងការសន្យារបស់ខ្លួនថា នឹងដាក់បញ្ជីនៅក្នុងពេលវេលាសមស្រប[2]។

3. ទោះបីជាយ៉ាងនេះក្តី សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅប្រកាន់ទស្សនៈរបស់ខ្លួនថា ជាការចាំបាច់ដែលអង្គជំនុំជម្រះតុលាការកំពូល (“អង្គជំនុំជម្រះ”) ត្រូវកំណត់កាលបរិច្ឆេទ។ ពេលវេលាជាងបីខែបានកន្លងផុតទៅហើយ បន្ទាប់ពីការដាក់សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី[3] ហើយទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងការិយាល័យសហព្រះរាជអាជ្ញា (“ក.ស.ព”) បានដំណើរការដោយមានពេលវេលាកំណត់ ដើម្បីឆ្លើយតប។ សហមេធាវីនាំមុខ និង ក.ស.ព មិនគួរតម្រូវឱ្យធ្វើដូច្នេះ ដោយផ្អែកលើមូលដ្ឋាននៃឯកសារ ដែល សូម្បីមេធាវីការពារក្តី ក៏បានទទួលស្គាល់ថាមិនគ្រប់គ្រាន់ដែរនោះ។

4. ចម្លើយតបរបស់មេធាវីការពារក្តី ក៏បានបញ្ជាក់ផងដែរថា សារណាបណ្តឹងសារទុក្ខ អាចក្លាយជាកម្មវត្ថុនៃការកែតម្រូវ ដែលមិនទាន់បានដាក់នៅឡើយ[4]។ ការគិតគូរពីភាពយុត្តិធម៌ និងភាពឆាប់

---

[1] ឯកសារ F56/2 *ចម្លើយតបរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់* ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ (“ចម្លើយតបមេធាវីការពារក្តី”)។

[2] ចម្លើយតបមេធាវីការពារក្តី កថាខណ្ឌ ៦។

[3] ឯកសារ F54 សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (សំណុំរឿង ០០២/០២) ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ (“សារណាបណ្តឹងសាទុក្ខ”) (ត្រូវបានជូនដំណឹងនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០)។

[4] ចម្លើយតបមេធាវីការពារក្តី កថាខណ្ឌ ៦។

របស់ តម្រូវថា ការដាក់ឯកសារទាំងអស់នេះ ត្រូវធ្វើឡើងឱ្យបានឆាប់របស់បំផុត ជាពិសេសក្នុងករណីដែល ពេលវេលាសម្រាប់ឆ្លើយតប មានការកំណត់។ គ្រោះថ្នាក់ធ្ងន់ធ្ងរជាពិសេសអាចនឹងកើតមាន ប្រសិនបើការកែតម្រូវដែលមានសារៈសំខាន់[5] (ឧទាហរណ៍ ការផ្លាស់ប្ដូរមូលដ្ឋានសំអាងផ្លូវច្បាប់ ដែលបានយោងនៅជើងទំព័រ) ត្រូវបានអនុញ្ញាតឱ្យធ្វើឡើង នៅពេលចុងក្រោយនៃដំណើរការ លទ្ធផលគឺថា មេធាវីការពារក្ដីមានពេលវេលាបន្ថែមគ្រប់គ្រាន់ ដើម្បីរៀបចំសារណារបស់ពួកគេ ហួសពីកាលបរិច្ឆេទកំណត់ដែលបានផ្ដល់ឱ្យ ប៉ុន្តែបានកាត់បន្ថយពេលវេលា ដែលភាគីដទៃទៀតទទួលបាន ដើម្បីដាក់ចម្លើយតបប្រកបដោយអត្ថន័យ។ ពិតជាមានហានិភ័យពិតប្រាកដដែលថា ការផ្លាស់ប្ដូរកាលបរិច្ឆេទកំណត់បន្ទាប់ អាចជាការចាំបាច់។ ការកែតម្រូវអាចចាំបាច់ត្រូវធ្វើឡើង ចំពោះឯកសារភាសាអង់គ្លេស និងឯកសារភាសាខ្មែរ នៃសារណាបណ្ដឹងសាទុក្ខ ដែលអាចនឹងបន្ថែមដល់ការពន្យាពេលទៀត។ ហេតុដូច្នេះ សហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំបន្ថែមដល់អង្គជំនុំជម្រះ ឲ្យកំណត់កាលបរិច្ឆេទសម្រាប់ការដាក់ រាល់ការកែតម្រូវនានា ទៅលើសារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី និងធ្វើការបញ្ជាក់បំភ្លឺថា មិនមានការអនុញ្ញាតឱ្យធ្វើការកែតម្រូវដែលមានសារៈសំខាន់ លើអង្គសេចក្ដីឡើយ។

5. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក៏ពិចារណាថាមានភាពចាំបាច់ ក្នុងការឆ្លើយតបចំពោះការស្នើសុំពីមេធាវីការពារក្ដីដែលថា ការពន្យាពេលក្នុងការដាក់ឯកសារកែតម្រូវ គឺមានយុត្តិកម្មបាន ដោយសារបញ្ហាធនធានមានកម្រិត។ ភាគីទាំងអស់រួមទាំងសហមេធាវីនាំមុខ តំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុទ្ធតែបំពេញការងារដោយមានធនធានមានកម្រិត។ ធនធានមានកម្រិតមិនអាចធ្វើឱ្យមានយុត្តិកម្មសម្រាប់ការពន្យាពេលរាប់ខែ ហួសកាលបរិច្ឆេទកំណត់របស់តុលាការឡើយ។ ប្រសិនបើមេធាវីការពារក្ដីជឿជាក់ថា ពួកគេត្រូវបានបដិសេធមិនផ្ដល់នូវធនធានគ្រប់គ្រាន់

---

[5] ចម្លើយតបមេធាវីការពារក្ដី មិនបានរៀបរាប់លម្អិត តើត្រូវកែតម្រូវអ្វីឡើយ ប៉ុន្តែជារឿងមិនច្បាស់លាស់សោះ ថាបើត្រឹមការកែតម្រូវដែលមិនមានលក្ខណៈសារៈសំខាន់ ហេតុអ្វីចំណាយពេលដល់ជាងបីខែដើម្បីកែ។ ឧទាហរណ៍ សូម្បីតែការបន្ថែមដែលមានសារៈសំខាន់តិចតួច ក៏ត្រូវ តុលាការព្រហ្មទណ្ឌអន្តរជាតិមិនអនុញ្ញាតដែរ។ *សូមមើល ព្រះរាជអាជ្ញា ជាមួយ Jean-Pierre Bemba Gombo* សេចក្ដីវិនិច្ឆ័យ ទៅលើបណ្ដឹងសាទុក្ខរបស់ព្រះរាជអាជ្ញា ប្រឆាំងនឹងទៅនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គបុរេជំនុំជម្រះ ស្ដីពីការដោះលែងបណ្ដោះអាសន្នទៅលើ Jean-Pierre Bemba Gombo និងការរៀបចំឱ្យមានសវនាការជាមួយរាជាណាចក្របែលហ្ស៊ិក សាធារណរដ្ឋប៉ទុយហ្កាល់ សាធារណរដ្ឋបារាំង សហព័ន្ធសាធារណរដ្ឋអាល្លឺម៉ង់ សាធារណរដ្ឋអ៊ីតាលី និងសាធារណរដ្ឋអាហ្វ្រិកខាងត្បូង, សំណុំរឿង ICC-01/05-01/08-631-Red ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០០៩ កថាខណ្ឌ ៣៧-៣៨ (សេចក្ដីដកស្រង់ដូចមានភ្ជាប់)។

ដើម្បីបំពេញបានតាមកាតព្វកិច្ចរបស់ខ្លួន បញ្ហានេះគួរត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ។ ដោយសារតែមេធាវីការពារក្តី បានអនុញ្ញាតឱ្យបញ្ហានេះ បង្ករជាការពន្យាពេលរាប់ខែ មុនពេលដាក់ឯកសារដែលបានកែតម្រូវ ដែលក្នុងអំឡុងពេលនោះ ពួកគេមិនបានលើកបញ្ហានេះជាផ្លូវការ ជម្រាបទៅភាគីនានា ឬអង្គជំនុំជម្រះនោះ តាមការពិតគឺភាគីដែលត្រូវដាក់ចម្លើយតបនោះទេ ដែលត្រូវមានហានិភ័យទទួលរងនូវព្យសនកម្ម។

## III. លក្ខខណ្ឌតម្រូវ សម្រាប់ឯកសារភ្ជាប់

6. ចម្លើយតបរបស់មេធាវីការពារក្តី អះអាងថា អនុស្សរណៈថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១១ របស់អង្គជំនុំជម្រះ ("អនុស្សរណៈអង្គជំនុំជម្រះតុលាការកំពូល") បានផ្តល់យុត្តិកម្មសម្រាប់ការណ៍ដែលមេធាវីការពារក្តី មិនបានភ្ជាប់មូលដ្ឋានសំអាងផ្លូវច្បាប់ជាច្រើន ដែលបានយោងនៅក្នុង សារណាបណ្តឹងសាទុក្ខរបស់ខ្លួន។ ក៏ប៉ុន្តែ អនុស្សរណៈអង្គជំនុំជម្រះតុលាការកំពូល គ្រាន់តែអនុញ្ញាតដល់ភាគីមិនចាំបាច់ផ្តល់ឯកសារភ្ជាប់ សម្រាប់ "មូលដ្ឋានសំអាងផ្លូវច្បាប់ ដូចជាយុត្តិសាស្ត្ររបស់តុលាការចំពោះកិច្ច និងលិខិតុបករណ៍អន្តរជាតិល្បីៗ ដែលមាននៅទីកន្លែងសារណា ហើយ**អង្គជំនុំជម្រះ និងភាគីទាំងអស់ អាចស្វែងរកបានដោយងាយស្រួល**" [ដោយគូសបញ្ជាក់បន្ថែម]។ អង្គជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា "មូលដ្ឋានសំអាងផ្លូវច្បាប់ ដែលមិនអាចរកបានដោយងាយស្រួល ចាំបាច់ត្រូវតែដាក់ជាមួយ បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ស្របតាមសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារ"។

7. មិនមានការបកស្រាយដោយសមហេតុផលណាមួយ ទៅលើអនុស្សរណៈអង្គជំនុំជម្រះតុលាការកំពូល អាចពង្រីកការលើកលែងនេះ ទៅដល់មូលដ្ឋានសំអាងផ្លូវច្បាប់ ប្រភេទដូចមានយោងនៅក្នុងជើងទំព័រ ១១ នៃសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីឡើយ[6]។ ក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្វែងរកឯកសារមួយចំនួន ដែលបានយោងនៅក្នុងសារណាបណ្តឹងសាទុក្ខ តែមិនទទួលបានជោគជ័យ ដែលការស្វែងរកនេះបង្ហាញថាឯកសារទាំងនោះមិន "ងាយស្រួលរកឡើយ"។ ការលំបាកគឺកាន់តែកើនឡើងដោយសារតែ ការមិនបញ្ចូល និង

[6] សហមេធាវីនាំមុខ រក្សាជំហររបស់ខ្លួនដែលថា ទោះបណ្ណាល័យរបស់ អ.វ.ត.ក មានសៀវភៅ ប៉ុន្តែមិនមែនមានន័យថា អង្គជំនុំជម្រះនិងភាគីនានា អាចស្វែងរកឯកសារបានគ្រប់ពេលនោះទេ។ ធនធានបែបនេះ អាចទទួលបាន ដោយអ្នកប្រើប្រាស់ ឬអ្នកខ្ចី ត្រឹមតែម្នាក់ ក្នុងមួយពេលប៉ុណ្ណោះ ហើយតម្រូវឱ្យមានវត្តមានដោយផ្ទាល់ នៅ អ.វ.ត.ក ទៀត។

កំហុសឆ្គងជាក់ស្តែង នៅក្នុងបញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ និងឯកសារយោងសារណាបណ្តឹងសាទុក្ខផ្ទាល់នោះ។ ក្នុងករណីខ្លះហាក់ដូចជាមាន ការដកស្រង់ដែលមិនត្រឹមត្រូវ និងមិនបានផ្តល់នូវឯកសារភ្ជាប់[7]។ ដោយសារតែកំហុសឆ្គងទាំងអស់នេះហើយ ទើបសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានការភ្ញាក់ផ្អើលជាមួយការអះអាង របស់មេធាវីការពារក្តីដែលថា "ឯកសារមូលដ្ឋានសំអាងផ្លូវច្បាប់ទាំងអស់ត្រូវបានយោងយ៉ាងលម្អិតនៅក្នុងសារណា"[8]។

8. សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី ពិតជាមិនមានការជំទាស់ ចំពោះការមិនបញ្ចូលពីឯកសារភ្ជាប់របស់មេធាវីការពារក្តី នូវលិខិតុបករណ៍អន្តរជាតិ ឬយុត្តិសាស្ត្រតុលាការចំពោះកិច្ចដែលអាចរកបាន ស្របទៅតាមអនុស្សរណៈអង្គជំនុំជម្រះតុលាការកំពូល។ ដូចគ្នានេះ ឯកសារដែលអាចរកបានប្រហែលគ្នា (ឧទាហរណ៍ យុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ) មិនចាំបាច់ត្រូវផ្តល់ឱ្យនោះទេ[9]។ ក៏ប៉ុន្តែ មូលដ្ឋានសំអាងផ្លូវច្បាប់ដទៃផ្សេងទៀត គួរត្រូវបានតម្រូវឱ្យផ្តល់ជូន។ ក្នុងករណីដែលមេធាវីការពារក្តីអះអាងថា ប្រភពណាមួយងាយស្រួលរកបាន ក្នុងលក្ខណៈដូចគ្នានឹងលិខិតុបករណ៍អន្តរជាតិ ឬយុត្តិសាស្ត្រអង្គជំនុំជម្រះចំពោះកិច្ច មេធាវីការពារក្តីអាចបង្ហាញយ៉ាងងាយ ដោយភ្ជាប់នូវអាសយដ្ឋានគេហទំព័រ (URL) សម្រាប់ឯកសារនេះនៅលើអនឡាញ។

## IV. ពេលវេលាបន្ថែមសម្រាប់បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

9. ចម្លើយតបរបស់មេធាវីការពារក្តី បានលើកទឡ្ហីករណ៍ថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវការពេលវេលាបន្ថែម សម្រាប់ការដាក់បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ របស់ពួកគេ

---

[7] ឧទាហរណ៍ ហាក់បីដូចជាមានកំហុសឆ្គងនៅក្នុង ឯកសារ F54 សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៧១ ជើងទំព័រ ៣៦៤ (យោង តុលាការកំពូល សភាព្រហ្មទណ្ឌ ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៣៤ ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ១៧៩; តុលាការកំពូល សភាព្រហ្មទណ្ឌ ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៨ ថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៥១; តុលាការកំពូល សភាព្រហ្មទណ្ឌ ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៥៧ ព្រឹត្តិបត្រព្រហ្មទណ្ឌលេខ ២៨៥).

[8] ចម្លើយតបមេធាវីការពារក្តី កថាខណ្ឌ ៩។

[9] សហមេធាវីនាំមុខ កត់សម្គាល់ថា ភាគីនានាជាញឹកញាប់គោរពតាមសេចក្តីណែនាំអនុវត្ត ហើយបានភ្ជាប់ឯកសារមូលដ្ឋានសំអាងផ្លូវច្បាប់ផងដែរ ដែលធ្វើឱ្យឯកសារទាំងនោះងាយស្រួលរកបាន សម្រាប់ភាគីដទៃទៀត អង្គជំនុំជម្រះ និងសាធារណជន។

ឡើយ ដោយមេធាវីការពារក្តីអះអាងថា (១) សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី មានពេលវេលាច្រើនហួរហៀរ ហើយពេលវេលាកំណត់ មិនទាន់បានចាប់ផ្តើមនៅឡើយ និង (២) មេធាវីការពារក្តី មិនបានទទួលអត្ថប្រយោជន៍ណាមួយឡើយ។

10. សម្រាប់ចំណុចទីមួយ ជាការគ្រប់គ្រាន់ដែលកត់សម្គាល់ថា ពេលវេលាកំណត់ដែលអង្គជំនុំជម្រះបានកំណត់ បានពិចារណារួចទៅហើយលើការពិតដែលថា នឹងមានអំឡុងពេលវេលាមួយ នៅចន្លោះពេលជូនដំណឹងអំពី សារណាបណ្តឹងសាទុក្ខជាភាសាបារាំង និង ឯកសារបកប្រែជាភាសាខ្មែរ។ ពេលវេលាកំណត់ទាំងអស់ ហើយនិងធនធានបន្តិចបន្តួច ដែលបានផ្តល់ជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានធ្វើឡើងដោយផ្អែកលើការសន្មតថា មេធាវីការពារក្តីនឹងគោរពតាម កាលបរិច្ឆេទកំណត់ដាក់ឯកសាររបស់ខ្លួន នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០។ មិនមាននរណាម្នាក់ដែលអាចប្រមើលមើលថា ការកែតម្រូវត្រូវបានទទួលនៅពេល ជាងបីខែក្រោយមកបែបនេះឡើយ។

11. ជាចុងក្រោយ ចម្លើយតបរបស់មេធាវីការពារក្តីបញ្ជាក់ថា "មេធាវីការពារក្តីមិនបានទទួលអត្ថប្រយោជន៍ណាមួយទាល់តែសោះ"។ តាមពិតទៅ មេធាវីការពារក្តី ទទួលបានអត្ថប្រយោជន៍ពីពេលវេលាបន្ថែមជាងបីខែ សម្រាប់ការដាក់បញ្ជីមូលដ្ឋានសំអាងផ្លូវច្បាប់ ដែលបានកែតម្រូវហើយ និងបង្រួបហើយ (ហើយប្រហែលជាសារណាបណ្តឹងសាទុក្ខ ដែលបានកែតម្រូវហើយដែរ)។ ជាលទ្ធផល អង្គជំនុំជម្រះគួរតែធានាថា ភាគីនានាមិនទទួលរងព្យសនកម្ម។

## V. សំណូមពរ

12. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំដោយសេចក្តីគោរព ចំពោះអង្គជំនុំជម្រះ៖

(១) **អនុញ្ញាត**តាមសំណើដែលបានស្នើឡើង នៅក្នុងសំណើរបស់សហមេធាវីនាំមុខ ពាក់ព័ន្ធនឹងករណីដែល ខៀវ សំផន មិនអនុវត្តតាមមាត្រា ៦ នៃសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារ[10]

[10] ឯកសារ **F56** *សំណើពាក់ព័ន្ធនឹងករណីដែល ខៀវ សំផន មិនអនុវត្តតាមមាត្រា ៦ នៃសេចក្តីណែនាំអនុវត្ត ស្តីពីការដាក់ឯកសារ* ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០។

(២) **បង្គាប់**ដល់មេធាវីការពារក្តីថា ការកែតម្រូវណាមួយ ទៅលើផ្នែកផ្សេងទៀតនៃសារណាបណ្តឹងសាទុក្ខ ចាំបាច់ត្រូវតែដាក់ ក្នុងពេលវេលាជាក់លាក់មួយ និង បញ្ជាក់ថាមិនមានការអនុញ្ញាតក្នុងការកែតម្រូវដែលមានលក្ខណៈសារៈសំខាន់។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ | ពេជ្រ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Megan HIRST<br>សហមេធាវីនាំមុខ | ទីក្រុងឡុងដ៍ | |